# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ នីកូឡា កូមជៀន (Nicholas Koumjian)**

**មុខងារ: សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ថ្ងៃទី ១៨ មិថុនា ឆ្នាំ ២០១៩**

**សម្ភាសន៍ដោយ: នីកូ ហេ្វលម៉ាន**

**បកប្រែបទសម្ភាសន៍ដោយ: រស់ សំពៅ**

*០០:២៧:០៧*

**១១ទំព័រ**

**នីកូល:** ខ្ញុំសូមចាប់ផ្តើមសួរសំណួរទៅលោកដោយខ្លីៗ អំពីប្រវត្តិរូបផ្ទាល់របស់លោកៗ លោកធ្លាប់មានបទពិសោធន៍ការងារជាង៣៥ឆ្នាំ ដែលក្នុងនោះភាគច្រើនបានពាក់ព័ន្ធនឹងការងាររបស់តុលាការយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិៗ តើលោកអាចផ្តល់ឲ្យដឹងបានទេ ថាកត្តាអ្វីទៅដែលនាំឲ្យលោកបានមកបំរើការងារនៅក្នុង អ.វ.ត.ក?

**កូមជៀន:** បាទ ខ្ញុំត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិៗ ខ្ញុំបានទទួលការហៅតាមទូរស័ព្ទរយៈពេលមួយថ្ងៃ ដើម្បីធ្វើការសម្ភាសសម្រាប់តំណែងនេះៗ ខ្ញុំគិតថា គឺប្រហែលជានៅក្នុងឆ្នាំ២០០៧ ឬ ២០០៨ ហើយនៅពេលនោះ ខ្ញុំបានកំពុងធ្វើការលើសំណុំរឿងមួយរបស់លោក Charles Taylor នៅក្នុងតុលាការពិសេសមួយសម្រាប់ប្រទេសសេរ៉ាឡេអូនៗ ដូច្នេះ បន្ទាប់ពីខ្ញុំត្រូវបានតែងតាំងដោយអង្គការសហប្រជាជាតិ ខ្ញុំក៏បានក្លាយជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងៗ ក្នុងឆ្នាំ២០១៣ នៅពេលដែលសំណុំរឿង០០២/០១ ត្រូវបានបញ្ចប់ការកាត់ទោសជាលើកដំបូងបង្អស់របស់ នួនជា និង ខៀវសំផន ខ្ញុំក៏ត្រូវបានស្នើសុំឱ្យមកជំនួសក្នុងមុខតំណែងរបស់សហព្រះរាជអាជ្ញាអន្តរជាតិម្នាក់ ដែលគាត់បានចាកចេញពីតួនាទីៗ ដូច្នេះខ្ញុំបានចូលរួមក្នុងតុលាការនេះចាប់តាំងថ្ងៃទី០១ ខែតុលា ឆ្នាំ២១០៣ៗ ហើយដូចអ្វីដែលបានកំពុងដំណើរការនេះ យើងក៏បានកំពុងរៀបចំសម្រាប់ការជជែកដេញដោលបញ្ចប់ក្នុងករណីនោះ ដែលនឹងកើតឡើងនៅចុងសប្តាហ៍នៃខែក្រោយនេះៗ

**នីកូល:** ចាស៎ មែនហើយៗ តើលោកអាចប្រាប់យើង អំពីទិដ្ឋភាពវិជ្ជមាននិងអវិជ្ជមាននៃតុលាការចម្រុះនេះបានទេ? មានការដាក់កំហិតរឹតត្បិតតឹងរឹង ឬ មានសេរីភាពពេញលេញដែលបានកើតឡើងនៅក្នុង អ.វ.ត.កៗ

**កូមជៀន**: ដំបូងបង្អស់យើងគួរតែទទួលស្គាល់ថា គ្រប់តុលាការជាតិទាំងអស់ ត្រូវមានកាតព្វកិច្ចធ្វើការកាត់ទោសលើគ្រប់ករណីនៃបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរបំផុតៗ ស្ថិតក្រោមសន្ធិសញ្ញាអំពើប្រល័យពូជសាសន៍ គឺមិនសំដៅដើម្បីកាត់ទោសតែលើអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានទទួលស្គាល់ជាទូទៅដោយអ្នកប្រាជ្ញភាគច្រើនទៀតថា ត្រូវតែមានកាតព្វកិច្ចធ្វើការកាត់ទោសចំពោះអ្នកទាំងឡាយណា ដែលជាប់ពាក់ពន្ធ័នឹងបទល្មើសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្រោមអនុសញ្ញាទីក្រុងហ្សឺណែវផងដែរៗ ច្បាប់មានកាតព្វកិច្ចមួយដើម្បីដាក់ទណ្ឌកម្មទៅលើជនជាតិរបស់ខ្លួន ដែលជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មសង្គ្រាម ឬ ជនជាតិដ៏ទៃទៀតដែលស្ថិតនៅលើទឹកដីរបស់ខ្លួន ហើយបានជាប់ពាក់ព័ន្ធក្នុងបទឧក្រិដ្ឋកម្មសង្គ្រាមៗ ប៉ុន្តែជាការពិតណាស់ មិនមែនគ្រប់ប្រទេសទាំងអស់នោះទេ ជាពិសេសសម្រាប់បណ្តាប្រទេសដែលទើបនឹងបញ្ចប់ជម្លោះ គឺត្រូវតែមានសមត្ថភាពដើម្បីធ្វើការងារលើសំណុំរឿងបែបនេះៗ ក្នុងប្រទេសខ្លះនៅតែមានការបែងចែកគ្នានៅក្នុងសង្គមមានការស្អប់ខ្ពើមគ្នានិងមានការមិនទុកចិត្តគ្នាយ៉ាងច្រើន ដែលនោះជាការលំបាកយ៉ាងខ្លាំងសម្រាប់ប្រព័ន្ធយុត្តិធម៌ជាតិ ហើយដែលត្រូវបានចាត់ទុកថាជាភាពស្របច្បាប់សម្រាប់គ្រប់ភាគីនិងពលរដ្ឋទាំងអស់នៃប្រទេសនោះៗ ប៉ុន្តែក្នុងករណីនីមួយៗក៏ទទួលបានផលប្រយោជន៍ជាក់លាក់ណាមួយដែលបានជាប់ពាក់ព័ន្ធនឹងអន្តរជាតិផងដែរៗ ក្នុងចំណោមប្រទេសទាំងនោះ ក៏មានប្រទេសជាច្រើនផងដែរ ដែលជាបណ្តាប្រទេសទើបនឹងបញ្ចប់ពីជម្លោះ ហើយដែលមិនមានសមត្ថភាព និងមិនមានការបណ្តុះបណ្តាលដល់ចៅក្រមនានាៗ ឧទាហរណ៍: នៅប្រទេសទីម័រខាងកើត ក្រោយពេលដែលទទួលបានឯករាជ្យ គឺគ្មាននរណាម្នាក់នៅក្នុងប្រទេសនេះជាព្រះរាជអាជ្ញា ឬចៅក្រមទេៗ នៅប្រទេសបូស្នៀ និង ហឺហ្គោវីណា ពួកគេបានបង្កើតអង្គជំនុំជម្រះលើបទឧក្រិដ្ឋកម្មសង្គ្រាមជាតិ នៅក្នុងប្រព័ន្ធតុលាការជាតិរបស់ពួកគេ ប៉ុន្តែនៅដើមឆ្នាំដំបូងបង្អស់ ពួកគេបានអញ្ជើញរដ្ឋអាជ្ញាអន្តរជាតិនិងចៅក្រមអន្តរជាតិឱ្យធ្វើការជាមួយជនរួមជាតិរបស់គេៗ ហើយផ្នែកមួយនៃបញ្ហានោះដោយសារតែប្រទេសនេះ គឺនៅមានការបែកបាក់គ្នានៅឡើយៗ ដូច្នេះប្រសិនបើ មានករណីប្តឹងប្រឆាំងនឹងជនជាតិភាគតិចនៅប្រទេសបូស្នៀ ពួកគេប្រហែលជានឹងនិយាយថា ជនជាតិម៉ូស្លីមបូស្នៀរ ឬ ជនជាតិបូស្នៀរសើបបៀរៗ ជាពិសេសប្រសិនបើ ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មនោះ គឺជាក្រុមជនជាតិភាគតិច ភាពមិនយុត្តិធម៌មិនលំអៀងនិងមិនគោរពតាមភាពលម្អៀងឬភាពមិនលំអៀង គឺជាគោលការណ៍ច្បាប់របស់ចៅក្រមៗ ដូច្នេះមានការចូលរួមពីសមាសភាពអន្តរជាតិនៅក្នុងអង្គជំនុំជម្រះមួយ ខ្ញុំជឿជាក់ថា ការវិនិច្ឆ័យទោស គឺត្រឹមត្រូវនិងយុត្តិធម៌ ហើយមិនប្រកាន់បក្សពួកសម្រាប់ភាគីណាមួយនៃជម្លោះឬភាគីណាមួយផ្សេងទៀតនោះទេៗ

ប្រសិនបើប្រៀបធៀបទៅនឹងតុលាការអន្តរជាតិនានា ជាពិសេសនៅពេលដែលគេបានបង្កើតតុលាការទាំងនោះនៅខាងក្រៅទីតាំងរបស់តុលាការអន្តរជាតិ វាពិតជាមានអត្ថប្រយោជន៍ដ៏ធំធេងណាស់ ដែលមានតុលាការកាត់ក្តីមួយបានបង្កើតនៅក្នុងប្រទេសនោះៗ ខ្ញុំជឿជាក់លើតុលាការអន្តរជាតិទាំងអស់ ដូច្នេះជាឧទាហរណ៍ សម្រាប់តុលាការអ.វ.ត.ក វាគឺជាតុលាការមួយដែលមានប្រជាជនយ៉ាងច្រើនបានមកចូលរួមស្តាប់និងតាមដានមើលរាល់គ្រប់ដំណើរការនីតិវិធីនៅក្នុងតុលាការៗ ខ្ញុំជឿជាក់ថា មានប្រជាជនខ្មែរប្រហែលជាជិតកន្លះលាននាក់បានមកទស្សនកិច្ចនៅតុលាការនេះៗ ពិតប្រាកដណាស់ ខ្ញុំជឿជាក់ថា មានមនុស្សរាប់រយរាប់ពាន់នាក់ យ៉ាងហោចណាស់មាន២០០.០០០នាក់ បានមកតាមដានមើលផ្នែកខ្លះនៃដំណើរការសវនាការកាត់ក្តីរបស់តុលាការនេះៗ នេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ យើងបានកំពុងធ្វើការងារមួយសម្រាប់ប្រជាពលរដ្ឋទាំងអស់នោះ ដែលត្រូវបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសាររបបមួយ និងរួមទាំងអ្នកដែលធ្លាប់បានចូលរួមចំណែកធ្វើការនៅក្នុងរបបនោះផងដែរៗ

**នីកូល:** ចាស៎! ពិតប្រាកដហើយ ដែលលោកបានធ្វើឱ្យខ្ញុំយល់ច្រើនៗ

ដូច្នេះសូមលោកនិយាយរៀបរាប់បន្តិច អំពីបញ្ហាប្រឈមនានាៗ តើលោកអាចផ្តល់នូវមតិយោបល់ អំពីបញ្ហាប្រឈមនានា ក្នុងនាមលោកជាព្រះរាជអាជ្ញាអន្តរជាតិដែលបានបំរើការងារនៅក្នុង អ.វ.ត.ក ដែរឬទេ?

**កូមជៀន:** ពិតហើយ ពេលណាអ្នកកំពុងធ្វើការនៅលើសំណុំធំៗ ដែលពាក់ព័ន្ធនឹងមេដឹកនាំកំពូលបញ្ហាប្រឈមធំបំផុតនោះ គឺអ្នកបានកំពុងតែព្យាយាមប្រមូលផ្តុំនិងរៀបចំសំណុំរឿងមួយដែលបានបង្ហាញឱ្យឃើញនូវអ្វីៗបានកើតឡើងថា ហេតុអ្វីបានជាមេដឹកនាំទាំងនោះត្រូវតែទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មដែលបានកើតជាញឹកញាប់នៅក្នុងភូមិមួយដែលមេដឹកនាំទាំងនោះមិនធ្លាប់បានទៅដល់ទីនោះ និងមិនធ្លាប់បានប្រព្រឹត្តបទល្មើសដោយផ្ទាល់ទៅលើជនរងគ្រោះ ហើយព្រមទាំងមិនធ្លាប់បានជួបទាក់ទងដោយផ្ទាល់ជាមួយនឹងជនដៃដល់ដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មនោះទាល់តែសោះៗ ដូច្នេះ នេះគឺជាបញ្ហាប្រឈមដ៏ធំមួយ ហើយក្នុងករណីនេះ ខ្ញុំអាចនិយាយបានថាសាលាក្តីខ្មែរក្រហមឬសាលាក្តីអ.វ.ត.ក គឺជាតុលាការមួយសម្រាប់ដោះស្រាយសំណុំរឿងបទឧក្រិដ្ឋកម្មដែលមានចំនួនជនរងគ្រោះច្រើនបំផុត "វិសាលភាពនៃអំពើឧក្រិដ្ឋកម្ម មិនចាំបាច់កំណត់លើចំនួនជនរងគ្រោះច្រើនឬតិចនោះទេ"ៗ ពិតជាមានការលំបាកខ្លាំងណាស់ ក្នុងការកំណត់ចំណាត់ថ្នាក់ចំពោះភាពសាហាវឃោរឃៅព្រៃផ្សៃទាំងនោះៗ ភាពសាហាវឃោរឃៅព្រៃផ្សៃទាំងនោះ គឺមិនអាចទទួលយកបានទេ ដោយសារ

ចំនួនជនរងគ្រោះនៃរបបខ្មែរក្រហមមានស្មើរតែទូទាំងប្រទេសទាំងមូល ហើយព្រមទាំងមានការរារាំងចំពោះកម្មាភិបាលរាប់ពាន់នាក់ដែលបានទទួលផលប្រយោជន៍ពីរបបនេះ។

ប្រជាជននៅរស់រានមានជីវិត៨លាននាក់ផ្សេងទៀត ត្រូវបានទទួលរងការឈឺចាប់ដោយវិធីផ្សេងៗពីគ្នា។ ប្រជាជនស្ទើរតែទាំងអស់ត្រូវបានគ្រប់គ្រងដោយរបបមួយ ដែលត្រូវបានចោទថាបានប្រព្រឹត្តនូវបទឧក្រិដ្ឋកម្មជាប់ពាក់ពន្ធ័បទឧក្រិដ្ឋអន្តរជាតិ ការដាក់ឲ្យធ្វើជាទាសកនិងការបាត់បង់សេរីភាពរបស់ពួកគេក្រោមការគ្រប់គ្រងដោយរបបនេះ។ ចំពោះអ្នកដែលបានស្លាប់បាត់បង់ជីវិត គឺវាមានការលំបាកយ៉ាងខ្លាំងក្នុងការផ្តល់នូវតួលេខពិតប្រាកដ ប៉ុន្តែបើយោងលើការសិក្សាស្តីពីសម្រង់ស្ថិតិប្រជាជនថ្មីៗនេះ គឺបានបង្ហាញថាមានមនុស្សជិត២លាននាក់ជាមធ្យមបានបាត់បង់ជីវិតក្នុងរបបនោះក្នុងរយពេលជិត៤ឆ្នាំ ដែលមានប្រហែលជាជិត២៥%នៃប្រជាជនជនសរុប។ ដូច្នេះ តើអ្នកត្រូវធ្វើយ៉ាងដូម្តេចដើម្បនិយាយដាក់បន្ទុកអ្នកនឹងមិនអាចនិយាយមិនដាក់បន្ទុកសាក្សីដែលបង្ហាញអំពីអ្វីដែលកើតឡើងចំពោះអ្នកទាំងអស់នោះបានទេ ហើយអ្នកនឹងត្រូវតែដាក់ភស្តុតាងបន្ថែមមិនត្រឹមតែបទឧក្រិដ្ឋកម្មដែលបានកើតឡើងទាំអស់នោះទេ ប៉ុន្តែអ្នកត្រូវគិតថា ហេតុអ្វីបានជាបទឧក្រិដ្ឋកម្មទាំងអស់គឺត្រូវតែផ្សារភ្ជាប់ទៅនឹងមេដឹកនាំទាំងនោះ។ ដូច្នេះនោះហើយគឺជាបញ្ហាប្រឈមដ៏អស្ចារ្យមួយ។ ខ្ញុំបានគិតថា យើងពិតជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ហើយខ្ញុំក៏គិតដែរថាយើងនឹងទទួលបានលទ្ធផលដ៏ល្អប្រសើរ។ ខ្ញុំបានគិតថា យើងបានបង្ហាញអង្គហេតុជាច្រើនតាមរយៈសវនាការដែលបានប្រព្រឹត្តឡើងតាំងតែពីមុនរហូតមកដល់បច្ចុប្បន្ននេះ។ ឧទាហរណ៍: អ្វីៗដែលបានកើតឡើងនៅក្នុងការដ្ឋានការងារនិងសហករណ៍ ការមិនបានថែទាំនិងយកចិត្តទុកដាក់ចំពោះប្រជាជន ការបង្ខិតបង្ខំឱ្យរៀបការ និងការបង្ខិតបង្ខំឲ្យរួមដំណេកដោយគ្មានការសុំការអនុញ្ញាតឬការយល់ព្រមព្រៀងដោយដៃគូរ។ យើងបានបង្ហាញអំពីមន្ទីរធ្វើទារុណកម្មមន្ទីរសន្តិសុខនានា និងហេតុការកើតឡើងនានាដែលមិនគួរឲ្យជឿដោយសាររបបនេះបាននាំឱ្យកើតមាននូវការធ្វើទារុណកម្ម ការកាប់សម្លាប់ដ៏ឃោរឃៅ និងចំនួនមនុស្សស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយដែលត្រូវបានលើកយកមកគិតពិចារណា នឹងដាក់ជាការមន្ទិលសង្ស័យ។ ករណីទាំងអស់នេះ ក្នុងទស្សនៈរបស់ខ្ញុំផ្ទាល់ ខ្ញុំគិតថាអ្វីៗដែលបានកើតឡើងគឺវានៅចំពេលដែលរបបមួយគ្មាននីតិរដ្ឋអ្វីទាំងអស់។ របបនេះគ្រាន់តែសម្រេចចិត្តដោយងាយៗបំផុត គឺវាអាចធ្វើអ្វីៗបានគ្រប់បែបយ៉ាងដែលខ្លួនចង់ធ្វើចំពោះមនុស្សគ្រប់រូប ដោយរួមទាំងការកាប់សំលាប់ដោយគ្មានដំណើរការនៃការដាក់មន្ទិលសង្ស័យថាមិនស្មោះត្រង់ចំពោះនយោបាយសម្រាប់មេដឹកនាំកំពូលរបស់ពួកគេ។

**នីកូល:** ដូច្នេះជាការពិត ថាតើលោកអាចភ្ជាប់នូវរឿងរ៉ាវទាំងអស់ដែលបានកើតឡើងពេលនោះ ដោយរបៀបណាទៅនឹងមេដឹកនាំទាំងអស់នោះ?

**កូមជៀន:** នោះគឺជាដំណើរការដ៏ស្មុគស្មាញមួយ ហើយត្រូវផ្អែកទៅលើភស្តុតាងពិតរបស់សំណុំរឿងនីមួយៗ និងបុគ្គលម្នាក់ៗ ប៉ុន្តែជាទូទៅអ្វីៗដែលយើងត្រូវលើយកភស្តុតាងមកបង្ហាញនោះ គឺយើងត្រូវបង្ហាញទៅលើសំណុំរឿងជារួមនិងមានលក្ខណៈធ្ងន់ធ្ងរ ហើយដែលនឹងត្រូវបង្ហាញភស្តុតាងថា វាគឺមានលក្ខណៈជាប្រពន្ធ័ៗ ឧទាហរណ៍: ការចេញសេចក្តីសម្រេចនានាគឺមិនត្រូវបានគេធ្វើការសម្រេចដោយងាយៗ ដោយមេបញ្ជាការថ្នាក់មូលដ្ឋានណាម្នាក់ក្នុងថ្នាក់ស្រុកនោះទេ។ ភស្តុតាងទាំងនោះហើយគឺជាអ្វីៗដែលបានកើតឡើង ដូចជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺមិនបានកើតឡើងតែមួយកន្លែងនោះទេ ប៉ុន្តែបានកើតឡើងទូទាំងប្រទេស។ ហេតុការណ៍នេះមិនបានកើតឡើងមុនពេលដែលរបបនេះជ្រើសរើសប្រជាជនជាដៃគូរទេ។ ហើយវាក៏មិនបានកើតឡើងចាប់តាំងតែពីមុនរបបនេះបានជ្រើសរើសឬបញ្ជាឱ្យប្រជាជនមានការរៀបការដែរ ប៉ុន្តែវាបានកើតឡើងនៅទូទាំងប្រទេសនៅក្នុងកំឡុងពេលនៃរបបខ្មែរក្រហម។ យើងបានសម្លឹងមើលដោយប្រុងប្រយ័ត្ន គ្រប់ការផ្តល់សេចក្តីកម្មរបស់ជនជាប់ចោទដែលបានបង្ហាញថា ពួកគេបានចូលរួមចំណែកក្នុងគោលនយោបាយនោះហើយព្រមបានទាំងគាំទ្រដល់គោលនយោបាយទាំងនោះផងដែរ។ យើងបានមើលលើគ្រប់ប្រភេទឯកសារទាំងអស់ដែលជាប្រភេទឯកសាររស់។ ក្នុងន័យនេះ យើងមានសំណាងខ្លាំងណាស់នៅក្នុងអ.វ.ត.ក ពីព្រោះយើងបានឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានធ្វើការប្រមូលឯកសារទាំងនោះអស់រយពេលជាច្រើនឆ្នាំកន្លងមក។ ទាំងអស់នេះត្រូវបានសន្និដានផងដែរថា មានឯកសារនានាជាច្រើនទៀតដែលត្រូវបានបំផ្លិចបំផ្លាញដោយរបបនោះ ដូចជាឯកសារភស្តុតាងសំខាន់ៗមួយចំនួន រួមមានកំណត់ហេតុកិច្ចប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់មេដឹកនាំកំពូល។ល។

**នីកូល:** ចាស៎ អស្ចារ្យណាស់។ តើយើងនឹងត្រូវបន្តសំណួរទៀត? ឬ លោកចង់ពិសារទឹកបន្តិចសិនមុនពេលយើងនឹងបន្តសំណួរទៀត?

**កូមជៀន:** តើអ្នកត្រូវការរយៈពេលប៉ុន្មានសម្រាប់ការសម្ភាសន៍នេះ ដូច្នេះខ្ញុំនឹងមានគំនិតខ្លះទុកមុន?

**នីកូល:** ខ្ញុំគិតថា ខ្ញុំនឹងត្រូវការពេលវេលាប្រហែលជា២០ទៅ៣០នាទីប៉ុណ្ណោះ ដើម្បីសួរលោកបន្ត។

**កូមជៀន:** តើចម្លើយទាំងនេះវាប្រវែងគ្រប់គ្រាន់សម្រាប់ អ្នកកំពុងចង់បានដែរឬទេ? តើអ្នកចង់បានចម្លើយខ្លីជាងនេះឬចម្លើយវែងជាងនេះ?

**នីកូល:** ដូច្នេះប្រសិនបើលោកអាចធ្វើវាខ្លីជាងនេះបាន នោះស្រេចតែលើលោកទេ។ ប៉ុន្តែប្រសិនបើលោកគិតថា វាត្រូវការពន្យល់បន្ថែមនោះវាពិតជាមិនអីទេសម្រាប់យើងក្នុងការសួរបន្ត។

**នីកូល**: *ត្រឹមត្រូវណាស់ៗ ដូច្នេះខ្ញុំចង់សួរលោកបន្តិចអំពីការងាររបស់លោកៗ លោកធ្លាប់បានធ្វើការនៅតុលាការអន្តរជាតិដទៃៗទៀតដូចជា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនៗ តើលោកមានចំណាប់អារម្មណ៍ដូចម្ដេចដែរចំពោះបទពិសោធន៍របស់លោកនៅក្នុងតុលាការទាំងនោះដោយប្រៀបធៀបជាមួយនឹងបទពិសោធន៍នៅក្នុងអ.វ.ត.ក?*

**កូមជៀន**: *មែនហើយ ក្នុងតុលាការនីមួយៗដែលខ្ញុំធ្លាប់បានធ្វើការនៅទីនោះគឺខុសគ្នាបន្តិចបន្តួចៗ ទោះបីជាខ្ញុំធ្លាប់ជាព្រះរាជអាជ្ញាក្នុងស្រុកអស់រយៈពេលជិត២០ឆ្នាំក្ដី ក៏វាមានភាពខុសប្លែកគ្នាតិចតួចដែរសូម្បីតែពីបន្ទប់សវនាការមួយទៅបន្ទប់សវនាការមួយទៀត ពីព្រោះដោយសារតែចៅក្រមម្នាក់ៗ គេមានលក្ខណពិសេសផ្ទាល់របស់ពួកគេ ជាពិសេសទាក់ទិនដំណើរការនិតិវិធីដែលពួកគេចង់ធ្វើការជំនុំជម្រះក្ដីៗ ការពិតណាស់ តុលាការនេះគឺជាតុលាការទី៦ហើយដែលខ្ញុំបានធ្វើការជាមួយៗ ខ្ញុំធ្លាប់បានធ្វើការនៅក្នុងសាលាក្ដីប្រទេសយូហ្គោស្លាវីៗ ខ្ញុំធ្លាប់ធ្វើជាព្រះរាជអាជ្ញានៅប្រទេសទីម័រខាងកើត ក្នុងអង្គភាពបទឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ និងក្នុងក្រុមពិសេសសម្រាប់បទឧក្រិដ្ឋកម្មធ្ងន់ធ្ងរផងដែរៗ ខ្ញុំធ្លាប់បានធ្វើការនៅក្នុងតុលាការរដ្ឋបូស្នៀនិងហឺហ្គោវីណាៗ បន្ទាប់មកទៀត ខ្ញុំបានធ្វើការនៅក្នុងតុលាការពិសេសមួយសម្រាប់ប្រទេសសៀរ៉ាឡេអូនៗ មុនពេលមកទីនេះ ខ្ញុំបានធ្វើការនៅតុលាការអាយស៊ីស៊ីមួយរយៈពេលខ្លីៗ តុលាការនីមួយៗមានភាពខុសគ្នាបន្តិចបន្តួច ហើយរឿងមួយដែលបានលេចធ្លោនៅក្នុងអ.វ.ត.ក គឺជាសំណុំរឿងមួយបានកើតឡើងនៅក្នុងប្រទេស ដូច្នេះនៅពេលដែលខ្ញុំបានធ្វើការលើសំណុំរឿងនេះ វាគឺជាបទចោទប្រកាន់ដំបូងបង្អស់នៅក្នុងតុលាការដែលមានជនរងគ្រោះជាច្រើនបានចូលរួមក្នុងនាមជាភាគីនានានៅក្នុងដំណើរការនីតិវិធីៗ ដូច្នេះវាខុសគ្នាខ្លាំងណាស់សម្រាប់ខ្ញុំ ក្នុងការឈរនៅក្នុងបន្ទប់តុលាការដើម្បីធ្វើសុន្ទរកថា ឬ និយាយជាមួយសាក្សី ហើយក៏បានដឹងផងដែរថានៅពីក្រោយខ្នងរបស់ខ្ញុំមានជនរងគ្រោះ១០នាក់ដែលពិតជាមានបទពិសោធន៍និងបានជួបប្រទះនូវអ្វីៗដែលបានកើតឡើងនៅក្នុងរបបនោះៗ*

**នីកូល**: *ខ្ញុំអាចស្រមៃឃើញនូវរូបភាព ដែលលោកបានកំពុងរៀបរាប់ប្រាប់ខ្ញុំ......*

**កូមជៀន**: *ជាការពិតណាស់ រឿងមួយទៀតក្នុងតុលាការអ.វ.ត.ក គឺទាក់ទិននឹងពេលវេលារបស់តុលាការរវាងបទឧក្រិដ្ឋកម្មនិងអង្គសវនការធំៗនានា ក្នុងចំណោមការងារដ៏ទៃទៀតដែលខ្ញុំធ្លាប់បានធ្វើកន្លងមកៗ ប្រហែលជាមុនពេលខ្ញុំបានមកទីនេះ ខ្ញុំបាននឹកស្រមៃថាមានមនុស្សជាច្រើននាក់ដែលពួកគាត់កំពុងតែព្យាយាមរំលឹកការចងចាំ ហើយនឹងនិយាយអំពីអ្វីៗដែលបានកើតឡើងតាំងពី៣០ឆ្នាំមុនៗ នៅពេលយើងបានមកដល់ទីនេះ ឥឡូវគឺមានរយពេល៤០ឆ្នាំហើយ បន្ទាប់ពីព្រឹត្តិការណ៍ទាំងនោះបានកើតឡើងៗ អ្វីៗដែលខ្ញុំបានប្រាប់ពួកគេ គឺមាន*

ពេលមួយ ស្ត្រីម្នាក់បាននិយាយអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងសវនាការ ពេលនោះនាងនៅតែនិយាយដោយកំហឹងក្នុងតុលាការ ចំពោះការមិនផ្តល់អាហារគ្រប់គ្រាន់ដល់ម្តាយរបស់នាង នឹងបានបណ្តាលម្តាយរបស់នាងបានស្លាប់ដោយសារការអត់ឃ្លាន ហើយវាហាក់បីដូចជារឿងរ៉ាវមួយដែលមិនមែនកើតឡើងកាលពី៤០ឆ្នាំមុនទាល់តែសោះ។ នៅពេលប្រជាជនបានមកផ្តល់សក្ខីកម្មក្នុងសវនាការ អ្នកអាចមានអារម្មណ៍ថា ការចងចាំរបស់ពួកគាត់បានបង្ហាញរូបភាពយ៉ាងច្បាស់នៅនឹងភ្នែក ហើយបានធ្វើឲ្យអ្នកមិនអាចបំភ្លេចនូវព្រឹត្តការណ៍ដែលកើតឡើងនៅពេលនោះ នៅក្នុងសំណុំរឿងនានាដែលអ្នកបានកំពុងតែធ្វើការជាមួយ។

**នីកូល:** ចាស៎ អស្ចារ្យណាស់ រឿងរ៉ាវនោះប្រាកដជាពិបាកណាស់។ ដូច្នេះប្រសិនបើ យើងគិតទៅពេលអនាគតខាងមុខ វាប្រហែលជាមិនមែនជាតុលាការចុងក្រោយដើម្បីដោះស្រាយអំពើឃោរឃៅដ៏ធ្ងន់ធ្ងរនោះទេ។ តើលោកអាចយល់ឃើញថា អ្វីទៅដែលជាបញ្ហាប្រឈមសម្រាប់តុលាការនាពេលអនាគត ហើយនឹងបានធ្វើការងារស្រដៀងគ្នានេះដែរ ដោយផ្អែកលើបទពិសោធន៍របស់លោកនៅក្នុងអ.វ.ត.ក?

**កូមជៀន:** អ្នកដឹងទេ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅមានលក្ខណៈក្មេងខ្ចីនៅឡើយ ហើយពិតជានៅមានភាពទន់ខ្សោយនិងកំហុសជាច្រើន។ ហើយអ្នកដឹងទៀតទេថា ចំនុចខ្សោយមួយក្នុងចំណោមចំនុចខ្សោយនានា ដែលប្រជាជនភាគច្រើនបានលើកយកមកនិយាយ គឺបានផ្អែកទៅលើកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាល។ តុលាការមិនមានប៉ូលីស តុលាការមិនអាចធ្វើការចាប់ខ្លួនជនណាម្នាក់បានឡើយ។ ហើយដើម្បីទទួលបានព័ត៌មានជាទូទៅ យើងត្រូវការកិច្ចសហការពីអាជ្ញាធរប៉ូលីសយុត្តិធម៌មូលដ្ឋាន។ ដូច្នេះទោះបីជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ តុលាការនៅយូហ្គោស្លាវី ឬ តុលាការនៅទីនេះក្តី តុលាការទាំងអស់នេះ គឺត្រូវតែផ្អែកទៅលើឆន្ទៈរបស់មេដឹកនាំនយោបាយ ដើម្បីឲ្យមានការធានាថាគ្មាននិទណ្ឌភាពណាមួយអាចនឹងមិនត្រូវបានលើកយកអនុវត្តនោះទេ។ ខ្ញុំគិតថា យើងនឹងត្រូវតែបន្តធ្វើការងារទាំងអស់នោះទៀត។ ខ្ញុំគិតថា ផ្នែកខ្លះៗនៃការងារដែលបានកំពុងតែធ្វើ គឺយើងបានធ្វើដោយសមរម្យនិងមានហេតុផលគ្រប់គ្រាន់ ហើយយើងនឹងមិនមានរបៀបវារៈនយោបាយទេ ប៉ុន្តែយើងបានកំពុងស្វែងរកយុត្តិធម៌សម្រាប់អ្វីៗដែលបានកើតឡើងពិតប្រាកដ។

ខ្ញុំមានក្តីសង្ឃឹមថា យើងនឹងមានការទទួលស្គាល់កាន់តែច្រើនពីសំណាក់ប្រជាពលរដ្ឋ ហើយក៏ត្រូវពឹងផ្អែកលើប្រជាពលរដ្ឋផងដែរ ចំពោះដាក់សម្ពាធលើទៅរដ្ឋាភិបាលដើម្បីឲ្យទទួលស្គាល់ថា អ្នកមិនអាចគ្រាន់តែផ្តល់ច្បាប់ក្រមព្រហ្មទណ្ឌជាតិឬព្រហ្មទណ្ឌអន្តរជាតិនានាឲ្យទៅភាគីម្ខាងទៀតដើម្បីយកទៅអនុវត្តបាននោះឡើយ។ ប្រសិនបើក្រុមយោធារបស់អ្នក

បានប្រព្រឹត្តនូវបទឧក្រិដ្ឋកម្មណាមួយ នោះពួកគេត្រូវតែប្រឈមនឹងការទទួលខុសត្រូវចំពោះរឿងរ៉ាវដែលខ្លួនបានប្រព្រឹត្ត។

**នីកូល**: ពិតមែនហើយ។ តើមានរឿងរ៉ាវណាមួយ នៅពេលខ្លះប្រហែលជានឹងអាចផ្លាស់ប្តូរទស្សនៈវិស័យ ឬ គំនិតយោបល់របស់លោក នៅពេលដែលលោកបានធ្វើការនៅអ.វ.ត.ក ដែរឬទេ?

**កូមជៀន**: អឺម! ...

**នីកូល**: ចម្លើយនេះ... អាចទទួលយកបាន!

**កូមជៀន**: គ្មានអ្វីបានផ្លាស់ប្តូរគំនិតខ្ញុំនោះទេ ...

**នីកូល**: ចាស៎ កុំបារម្ភអី។ ដូច្នេះតើមានរឿងរ៉ាវណាមួយរបស់ជនជាប់ចោទ ឬ អ្នករស់រានមានជីវិតដែលបាននិយាយប្រាប់និងនៅដក់ជាប់ជាមួយលោក ហើយដែលលោកនឹងចង់និយាយប្រាប់យើងដែរឬទេ?

**កូមជៀន**: មានប្រជាជនច្រើនណាស់។ នៅក្នុងប្រព័ន្ធច្បាប់ដែលយើងបានអនុវត្តនៅកម្ពុជា យើងមិនត្រូវបានអនុញ្ញាតឱ្យនរណាម្នាក់និយាយជាមួយសាក្សីជាមុនទេ នោះមានន័យថា យើងមានពេលវេលាតិចតួចណាស់ក្នុងការធ្វើអន្តរកម្មជាមួយពួកគាត់នៅក្នុងអង្គសវនាការ ប៉ុន្តែអ្វីៗដែលបានធ្វើឲ្យយើងមិនអាចបំភ្លេចបាននោះ នៅពេលនរណាម្នាក់បាននិយាយអំពីការជម្លៀសប្រជាជនដ៏គួរភ្ញាក់ផ្អើលចេញពីទីក្រុងភ្នំពេញ និងបានឃើញសាកសពមនុស្សស្លាប់នៅលើដងផ្លូវ នោះបានធ្វើឲ្យយើងដឹងយ៉ាងពិតប្រាកដថា នេះជាអ្វីៗដែលបានកំពុងកើតឡើងពិតប្រាកដ។ វាដូចជា ពួកគាត់មិនមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគ ការព្យាយាមដើម្បីរស់នៅក្នុងកំដៅថ្ងៃដ៏សែនក្តៅ និងបានឃើញទារកដែលត្រូវបានសំលាប់ក្នុងកំឡុងពេលនោះ។ មានប្រជាជនច្រើនណាស់ដែលធ្លាប់បានធ្វើកានៅតាមការដ្ឋាននានា ហើយបាននិយាយអំពីអ្វីៗដែលពួកគាត់ធ្លាប់បានរស់នៅនិងធ្វើការនៅទីនោះ និងពេលពួកគាត់មិនត្រូវបានផ្តល់អាហារគ្រប់គ្រាន់សម្រាប់បរិភោគ។ ហើយអ្នកដឹងទេថា មានប្រជាជនច្រើនណាស់បាននិយាយថា នៅពេលពួកគាត់បានទៅនិយាយបំភ្លឺនៅក្នុងតុលាការ ពួកគាត់ប្រាកដជានឹងមិននិយាយប្រាប់កូនៗរបស់គាត់ទេ។ ហើយមានអ្នកខ្លះទៀតបាននិយាយថា នៅពេលពួកគាត់និយាយប្រាប់កូនៗរបស់គាត់ កូនៗរបស់គាត់បាននិយាយថា ពួកគេមិនជឿនោះទេ ពីព្រោះការនិយាយប្រាប់នោះវាហាក់បីដូចជាប្រភេទរឿងមួយកំពុងធ្វើការឃោសនាឲ្យរដ្ឋាភិបាល។ ហេតុអ្វីបានជាអ្នកមិនទៅបេះផ្លែឈើយកមកហូប? ហេតុអ្វីបានជាអ្នកមិនទៅរកត្រីក្នុងទន្លេ? ពួកគេមិនបានយល់អំពីអ្វីៗនៅក្នុងរបបនោះទេ? វាមិនអាចទៅរួចទេ? ហេតុអ្វីបានជាអ្នកមិនជិះម៉ូតូ? ហើយហេតុអ្វីបានជាមានតែកម្មាភិបាលពីរបីនាក់ប៉ុណ្ណោះអាចត្រូវបានអនុញ្ញាតឱ្យជិះម៉ូតូ? បុរសម្នាក់បាននិយាយអំពីការបង្ខំឱ្យរៀបការ។ ជារឿយៗភាគច្រើននៃសំណុំរឿងទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ យើងបានផ្តោតជាពិសេសទៅលើផលវិបាកដ៏សាហាវនិងគួរឲ្យស្អប់ខ្ពើម ដែលបានប៉ះ

ពាល់លើស្ត្រីនៅក្នុងសង្គម។ ហើយការបង្ខំឱ្យរៀបការ ឬ ការបង្ខំមានទំនាក់ទំនងផ្លូវភេទនោះ គឺត្រូវបានពិចារណាថា បានធ្វើឲ្យស្ត្រីម្នាក់ត្រូវបានខូចខាតនិងរងផលវិបាកធ្ងន់ធ្ងរជារៀងរហូត។ ប៉ុន្តែក៏មានប៉ះពាល់ខ្លះៗដល់បុរសផងដែរ មានបុរសម្នាក់ដែលបាននិយាយអំពីរឿងរ៉ាវរបស់គាត់ដែលត្រូវបានបង្ខំឲ្យរៀបការក្នុងរបបនោះ ប៉ុន្តែក្រោយមកពួកគាត់បានបែកបាក់គ្នាវិញ តាមរយៈការបង្ខំឱ្យរៀបការនេះ។ ប៉ុន្តែច្រើនឆ្នាំក្រោយមក នៅពេលគាត់បានធ្វើដំណើរនៅតាមដងផ្លូវមួយក្នុងរាជធានីភ្នំពេញ ពួកគេបានជួបមុខគ្នា ហើយពួកគាត់បាននិយាយជាមួយគ្នាថា ពួកយើងទាំងពីរគឺជាពុទ្ធសាសនិកជន ហើយពួកយើងនឹងអាចជួបគ្នានិងបានរួមរស់នៅជាមួយគ្នាវិញក្នុងជាតិក្រោយ។

**នីកូល:** នោះគឺជារឿងរ៉ាវមួយដ៏អស្ចារ្យខ្លាំងណាស់។ សូមអរគុណចំពោះការចែករំលែក។ ដូច្នេះតាមរយៈរឿងរ៉ាវដ៏ធំៗទាំងនោះ តើលោកគិតថាមានផលប៉ះពាល់ដ៏សំខាន់ៗណាខ្លះនៅក្នុង អ.វ.ត.ក សម្រាប់សង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ ឬ ក្នុងពេលអនាគតជាច្រើនឆ្នាំខាងមុខ?

**កូមជៀន:** ខ្ញុំគិតថា សំខាន់បំផុត ប្រហែលជាទាក់ទងនឹងអ្វីៗដែលខ្ញុំបាននិយាយ។ ក្មេងៗជំនាន់ក្រោយមិនមានបទពិសោធន៍អំពីរបបនេះទេ។ នរណាម្នាក់នៅទីនេះ ដែលមានអាយុលើសពី ៥០ឆ្នាំ គឺគាត់បានចងចាំយ៉ាងច្បាស់ណាស់ ហើយមិនចាំបាច់មានការពន្យល់ណាមួយដល់ពួកគាត់ទេ នោះវាក៏ពិតជាគួរឱ្យរន្ធត់ណាស់ទៅហើយ។ ប៉ុន្តែបើសម្រាប់ក្មេងៗជំនាន់ក្រោយពួកគេមិនប្រាកដថាអ្វីៗដែលបានកើតឡើងនោះគឺជាការពិត ឬ មិនមែនជាការពិតនោះទេ ហើយពួកគេក៏យល់ដែរថា រឿងរ៉ាវទាំងនេះពិបាកនឹងជឿដោយសារការរកហេតុផលនានាការមកពន្យល់។ ខ្ញុំចង់និយាយថា រឿងរ៉ាវនេះមិនមែនជារឿងធម្មតាៗដែលនឹងអាចកើតឡើងបាននោះទេ។ តើរបបមួយអាចកើតឡើងបានយ៉ាងដូចម្តេច? តើធ្វើដូចម្តេចអាចមើលឃើញថាគ្រប់ទិដ្ឋភាពនៃលក្ខណជីវិតរបស់មនុស្សជាតិត្រូវបានគ្រប់គ្រងត្រឹមត្រូវ? តើហេតុអ្វីបានជាគេប្រាប់អ្នកឱ្យរៀបការជាមួយអ្នកដ៏ទៃដែលមិនធ្លាប់បានស្គាល់និងនិយាយគ្នាពីមុនមក? អ្នកនឹងមិនហ៊ាននិយាយបដិសេធន៍ ដោយសារតែរបបនោះអាចនឹងធ្វើមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់អ្នក ហើយក៏ប្រហែលជាអាចនឹងមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់សមាជិកគ្រួសាររបស់អ្នកផងដែរ។ ដូច្នេះវាពិបាកណាស់ ក្នុងការពន្យល់រឿងនេះដល់ក្មេងៗជំនាន់ក្រោយណាស់។ តាមពិតក្នុងប្រវត្តិរូបគ្រួសាររបស់ខ្ញុំ គឺឪពុករបស់ខ្ញុំ គាត់ជាជនជាតិអាមេរិចកាំង ហើយឪពុករបស់ខ្ញុំបានចាប់កំណើតនៅចំពាក់កណ្តាលពេលដែលអំពើប្រល័យពូជសាសន៍នៅក្នុងចក្រភពអូតូម៉ង់បានកើតឡើងនៅពេលនោះ។ អ្នកដឹងទេ ១០០ឆ្នាំក្រោយមក ប្រជាជនអាមេនីនៅតែព្យាយាមយកចិត្តទុកដាក់ និងបាននាំយកមកនូវការចងចាំដ៏ធំធេងមួយ ព្រមទាំងភាពដែលអាចទទួលយកបានឲ្យបានកាន់តែច្រើន ចំពោះអ្វីៗដែលបានកើតឡើងពិតប្រាកដនៅក្នុងប្រវត្តិសាស្ត្រដ៏សំខាន់របស់ខ្លួន។ ហើយសម្រាប់ប្រជាជន

*កម្ពុជា អ្វីៗដែលបានកើតឡើងនៅក្នុងអង្គសវនាការកាត់ក្តីនេះ ខ្ញុំបានគិតថាវាមានសារៈសំខាន់ណាស់ចំពោះ ចៅៗរបស់ប្រជាជនជំនាន់ដែលទើបតែមានកូនតូចៗ ហើយក៏នឹងមានសារៈសំខាន់ក្នុងរយៈពេលពី៥០ឆ្នាំ ទៅ១០០ឆ្នាំខាងមុខទៀត ដើម្បីធ្វើឲ្យពួកគេបានយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាៗ ហើយវាក៏ជាឧទាហរណ៍ដ៏ធំធេងផងដែរ សំរាប់ប្រទេសកម្ពុជានិងប្រទេសដទៃៗទៀត ចំពោះមេដឹកនាំផ្តាច់ការនិងអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មដ៏ឃោឃៅព្រៃផ្សៃបំផុតគ្រប់ទីកន្លែង ហើយដែលនឹងបានប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ច្បាប់អន្តរជាតិៗ ការកាត់សេចក្តីនេះប្រហែលជាមិនសូវល្អឥតខ្ចោះ ហើយក៏ប្រហែលជាមានការយឺតយ៉ាវបន្តិច ប៉ុន្តែអ្នកដែលប្រព្រឹត្តអំពើបទឧក្រិដ្ឋកម្មដ៏ឃោរឃៅព្រៃផ្សៃ ឬអ្នកដែលគ្រាន់តែត្រូវបានជឿជាក់ថាអាចនឹងមានអំណាចនៅក្នុងរបបនោះ គឺពួកគេនឹងមិនអាចគេចផុតអំពីអ្វីៗដែលខ្លួនបានប្រព្រឹត្តរហូតបាននោះទេ ហើយគង់តែមានថ្ងៃណាមួយពួកគេនឹងត្រូវបានរកឃើញ ហើយត្រូវតែប្រឈមនឹងការទទួលស្គាល់នូវអ្វីៗដែលខ្លួនធ្លាប់បានប្រព្រឹត្តនៅចំពោះមុខច្បាប់ៗ*

**នីកូល:** *ចាស៎ ខ្ញុំគិតថាធ្វើឱ្យខ្ញុំយល់បានច្រើនៗ ដូច្នេះជាថ្មីម្តងទៀតសម្លឹងមើលទៅមុខបន្តិច ខ្ញុំបានឮថាលោកនឹងធ្វើដំណើរទៅធ្វើការក្នុងសំណុំរឿងមួយទាក់ទងនឹងក្រុមរ៉ូហ៊ីងយ៉ាៗ តើលោកគិតថា លោកបានទទួលបទពិសោធន៏ការងារអ្វីខ្លះក្នុងអ.វ.ត.ក ហើយពិសោធន៏ការងារទាំងនេះនឹងជួយដល់ការងាររបស់លោក យ៉ាងណាខ្លះ?*

**កូមជៀន:** *ជាការពិតណាស់តំណែងបន្ទាប់របស់ខ្ញុំ គឺនឹងត្រូវបានតែងតាំងធ្វើជាប្រធានយន្តការស៊ើបអង្កេតឯករាជ្យថ្មីមួយសម្រាប់ប្រទេសមីយ៉ាន់ម៉ាៗ ហើយក្នុងអាណត្តិនេះ នឹងត្រូវបានរៀបចំសំណុំរឿងក្តីព្រហ្មទណ្ឌនានា ដែលបានពាក់ព័ន្ធនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឬ ច្បាប់អន្តរជាតិដទៃៗទៀត ប៉ុន្តែវាពាក់ព័ន្ធតែក្នុងប្រទេសនោះទាំងមូលប៉ុណ្ណោះ ហើយវាក៏មិនត្រូវបានកំណត់តែចំពោះក្រុមរ៉ូហ៊ីងយ៉ា ឬ ក្រុមជនជាតិណាមួយនោះទេៗ ប្រសិនបើប្រជាជននៅក្នុងប្រទេសមីយ៉ាន់ម៉ា គឺជាជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម នោះវាគឺជាការងារទទួលខុសត្រូវរបស់ខ្ញុំ ហើយអង្គភាពរបស់ខ្ញុំនឹងត្រូវធ្វើការស៊ើបអង្កេតប្រសិនបើវាជាអំពើឧក្រិដ្ឋកម្មអន្តរជាតិ ហើយនឹងត្រូវរៀបចំភស្តុតាងនានា ដើម្បីនឹងផ្តល់ជូនដល់តុលាការមួយដែលនឹងត្រូវបង្កើតឡើងក្នុងពេលបច្ចុប្បន្ននេះ ឬពេលអនាគតដែលនឹងអាចមានឆន្ទៈក្នុងការកាត់ទោសលើសំណុំរឿងទាំងអស់នោះៗ ដូច្នេះខ្ញុំគិតថា នេះជាបញ្ហាប្រឈមថ្មីសម្រាប់ខ្ញុំ ហើយការងារនេះវានឹងខុសគ្នាបន្តិចបន្តួចខ្លះដែរ ពីព្រោះខ្ញុំនឹងមិនបានឈរនៅក្នុងអង្គសវនការទេៗ ប៉ុន្តែអ្វីៗដែលខុសគ្នាអំពីការងារនានាមួយចំនួនទៀតដែលខ្ញុំធ្លាប់បានធ្វើ នោះវាគឺពិតជាបញ្ហាជម្លោះកំពុងតែកើតមានបន្តៗ យុត្តាធិការនេះ មិនបាន*

បញ្ចប់នៅក្នុងឆ្នាំ២០១៧នោះទេ ប៉ុន្តែវាបានចាប់ផ្តើមកើតឡើងតាំងពីឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ននេះ ហើយនៅតែបន្តមកដល់អនាគតទៀត។ ជាការពិតណាស់ អ្វីៗដែលកំពុងកើតឡើងនេះ គឺកំពុងតែប៉ះពាល់ដល់ជីវិតមនុស្សក្នុងពេលបច្ចុបន្ននេះ។ រៀងរាល់សប្តាហ៍គឺមានរបាយការណ៍ជាច្រើនស្តីពីការកាប់សម្លាប់និងអំពើហិង្សានានា ហើយយើងក៏បានដឹងដែរថាមានប្រជាជនប្រហែលមួយលាននាក់ចាកចេញពីប្រទេស និងមានប្រជាជនរាប់ពាន់នាក់ផ្សេងទៀតបានកំពុងផ្លាស់ទីលំនៅចេញពីប្រទេសរបស់ខ្លួន ដែលពេលបច្ចុប្បន្ននេះពួកគេកំពុងតែទទួលរងការឈឺចាប់។ ដូច្នេះវាគឺជាការងារមួយដែលមានលក្ខណប្រញាប់បន្ទាន់និងឆាប់រហ័សក្នុងចំណោមការងារផ្សេងៗទៀតដែលខ្ញុំមិនធ្លាប់បានបំពេញពីមុនមក។ ដូច្នេះវាអាចជាការងារខុសគ្នាខ្លះៗ ដែលខ្ញុំមិនមានការងារត្រូវបំពេញប្រញាប់បន្ទាន់ក្នុងពេលតែមួយនោះទេ។

**នីកូល:** ចាស៎ សូមអរគុណ។ មុនពេលយើងបង្វែរម៉ាស៊ីនថតចេញ តើលោកមានអ្វីចង់សួរយើងបន្ថែម ឬលោកគិតថាវាមានសារៈសំខាន់សម្រាប់យើង ដែរឬទេ?

**កូមជៀន:** ខ្ញុំគ្មានអ្វីបន្ថែមទៀតទេ។